# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០០២....សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិនា ឆ្នាំ២០១៦

# សារាចរណែនាំ
## ស្តីពី
## បែបបទរដ្ឋបាល និង នីតិវិធីហិរញ្ញវត្ថុ
## សម្រាប់នាយកដ្ឋាន និង អង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ក្នុងការចូលរួមអនុវត្តគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ហិរញ្ញប្បទានដោយថវិការដ្ឋ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជាច្រើន ដែលហិរញ្ញប្បទានដោយថវិការដ្ឋ "គម្រោងវិនិយោគផ្ទាល់" ក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ មានការចូលរួមអនុវត្តកាន់តែច្រើនពីអង្គភាពពាក់ព័ន្ធ ជាពិសេសអង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ដោយបានកើនឡើងរហូតដល់ចំនួន ២០ អង្គភាព ក្នុងនោះ មានអង្គភាពវិស្វកម្មមួយចំនួនពុំមានរចនាសម្ព័ន្ធ និង/ឬ លក្ខណៈសម្បត្តិច្បាស់លាស់។

អនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ក្នុងការបង្កើនប្រសិទ្ធភាពនៃការរៀបចំ គ្រប់គ្រង និង អនុវត្តគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ បានឯកភាពគ្នារៀបចំសារាចរណែនាំស្តីពី បែបបទរដ្ឋបាល និង នីតិវិធីហិរញ្ញវត្ថុ សម្រាប់នាយកដ្ឋាន និង អង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ក្នុងការចូលរួមអនុវត្តគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ហិរញ្ញប្បទានដោយថវិការដ្ឋ។

សារាចរនេះ មានគោលបំណងលើកកម្ពស់ និង ធានានូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និង គណនេយ្យភាព ក្នុងការគ្រប់គ្រងចំណាយឥណទានថវិកាវិនិយោគ សម្រាប់គម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ ដែលអនុវត្តដោយនាយកដ្ឋាន ឬអង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

សារាចរនេះ មានគោលដៅកែសម្រួលឡើងវិញនូវសមាសភាព សំដៅពង្រឹងសមត្ថភាពរបស់នាយកដ្ឋាន និង អង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ដោយតម្រូវឱ្យមានក្របខណ្ឌគតិយុត្តរចនាសម្ព័ន្ធអង្គភាព បែបបទរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុច្បាស់លាស់ ក្នុងការចូលរួមអនុវត្តគម្រោងស្ថាបនាស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដោយប្រើប្រាស់ថវិកាជាតិ។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ សូមធ្វើការណែនាំដូចតទៅ÷

**១- លក្ខណៈសម្បត្តិនៃនាយកដ្ឋាន និង អង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ**

-នាយកដ្ឋាន និង អង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ គឺជាអង្គភាពទាំងឡាយណាដែលបង្កើតឡើងដោយរាជរដ្ឋាភិបាល ក្នុងគោលដៅបម្រើឱ្យយុទ្ធសាស្ត្រការពារជាតិ រួមចំណែកក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ជាពិសេស តាមតំបន់ព្រំដែន តំបន់ព្រៃភ្នំ តំបន់មានយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងតំបន់ដទៃទៀត សំដៅពង្រឹងសមត្ថភាពជំនាញវិស្វកម្ម និង ចិញ្ចឹមចលនាកងទ័ពនិងនគរបាល ព្រមទាំងឆ្លើយតបនឹងតម្រូវការបន្ទាន់របស់រាជរដ្ឋាភិបាល។

-នាយកដ្ឋាន និង អង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ដែលមានបំណងចូលរួមអនុវត្តគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវមានអាជ្ញាបណ្ណផ្លូវថ្នល់ ចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

**២- អំពីបែបបទរដ្ឋបាល និង នីតិវិធីហិរញ្ញវត្ថុ**

ក- <u>វិធានការបែបបទរដ្ឋបាល</u>

-រាល់លិខិតស្នាម ដែលរៀបចំឡើងដោយនាយកដ្ឋាន ឬអង្គភាពវិស្វកម្ម ពាក់ព័ន្ធនឹងគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវមានហត្ថលេខា និងត្រារបស់ក្រសួង ស្ថាប័ន ឬរបស់នាយកដ្ឋាន ឬអង្គភាពវិស្វកម្ម ក្នុងករណីមានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ។

-រាល់លិខិតស្នើសុំទូទាត់ថវិកាដែលនាយកដ្ឋាន ឬអង្គភាពវិស្វកម្ម ផ្ញើជូនក្រសួងអាណាប័ក ត្រូវចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

-នាយកដ្ឋាន និង អង្គភាពវិស្វកម្ម ត្រូវជូនព័ត៌មានទៅអង្គភាពហិរញ្ញវត្ថុ នៃស្ថាប័នអាណាព្យាបាលនូវរាល់គម្រោងដែលទទួលបានពីក្រសួងអាណាប័ក។

## ២- វិធានការនីតិវិធីហិរញ្ញវត្ថុ

-នាយកដ្ឋាន ឬអង្គភាពវិស្វកម្មមួយ ត្រូវមានគណនីធនាគារមួយសម្រាប់គ្រប់គ្រងប្រតិបត្តិការចំណូលនិងចំណាយនៃគម្រោងទាំងឡាយដែលនាយកដ្ឋាន ឬអង្គភាពវិស្វកម្មនោះទទួលបាន។ នាយកដ្ឋាន និង អង្គភាពវិស្វកម្ម តាមរយៈអង្គភាពហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ឬអង្គភាពអាណាព្យាបាល ត្រូវស្នើសុំបើកគណនីធនាគារមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងផ្តល់ការអនុញ្ញាត។

-ក្នុងគោលដៅលើកកម្ពស់ការទទួលខុសត្រូវរបស់នាយកដ្ឋាន និង អង្គភាពវិស្វកម្ម ក្នុងការអនុវត្តគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អនុញ្ញាតឱ្យនាយកដ្ឋាន ឬអង្គភាពវិស្វកម្មចុះកិច្ចសន្យាផ្ទាល់ជាមួយក្រសួងអាណាប័ក ដោយអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ការចុះកិច្ចសន្យាផ្ទាល់នេះ តម្រូវឱ្យមានលិខិតផ្ទេរសិទ្ធិពីប្រធានក្រសួង ស្ថាប័ន ឬអង្គភាពអាណាព្យាបាល។

-ការស្នើសុំថវិកាសម្រាប់អនុវត្តគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវធ្វើឡើងតាមរយៈអង្គភាពហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ឬអង្គភាពអាណាព្យាបាល មកក្រសួងអាណាប័ក។ ការទូទាត់ថវិកាត្រូវធ្វើឡើងតាមលក្ខខណ្ឌនៃកិច្ចសន្យា ដោយផ្ទេរត្រង់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅនាយកដ្ឋាន ឬអង្គភាពវិស្វកម្មផ្ទាល់តែម្តង។

-នាយកដ្ឋាន និង អង្គភាពវិស្វកម្មត្រូវមានកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវនិងច្បាស់លាស់សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម និងអធិការកិច្ច ដោយស្ថាប័នមានសមត្ថកិច្ច។ ទន្ទឹមនេះ ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដោយត្រូវផ្ញើជូនក្រសួង ស្ថាប័ន ឬអង្គភាពអាណាព្យាបាលពាក់ព័ន្ធ។ ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសាធារណការនិងដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ អាចស្នើសុំរបាយការណ៍ហិរញ្ញវត្ថុបាន។

## ៣- ដំណាក់ការអន្តរកាល

-ក្នុងគោលបំណងបញ្ចៀសបាននូវការយឺតយ៉ាវក្នុងការសិក្សា រៀបចំ និងអនុវត្តគម្រោង បន្តសម្រួលការធ្វើដំណើររបស់ប្រជាជន និងសកម្មភាពសេដ្ឋកិច្ចពីតំបន់មួយទៅតំបន់មួយ ព្រមទាំងធានាបាននូវការធ្វើសមាហរណកម្មប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនទូទាំងប្រទេស ក្នុងដំណាក់កាលអន្តរកាល នាយកដ្ឋាន ឬអង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ដែលបច្ចុប្បន្នកំពុងអនុវត្តគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ (គម្រោងពហុឆ្នាំ) អាចអនុញ្ញាតឱ្យបន្តបញ្ចប់ការងារនៅក្នុងឆ្នាំ២០១៦ ឬឆ្នាំបន្តបន្ទាប់ តាមការជាក់ស្តែង។

-ចាប់ពីឆ្នាំ២០១៧ ទៅ ដើម្បីអាចចូលរួមអនុវត្តគម្រោងស្ថាបនា ស្តារ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់បាន នាយកដ្ឋាន និង អង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវមានអាជ្ញាបណ្ណផ្លូវថ្នល់ ចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ នាយកដ្ឋាន និង អង្គភាពវិស្វកម្មក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

| | | |
|---|---|---|
| **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងអភិវឌ្ឍន៍ជនបទ** | **ក្រសួងសាធារណការនិងដឹកជញ្ជូន** | **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** |
| **ជា សុផារ៉ា** | **ស៊ុន ចាន់ថុល** | **បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន** |

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ